# ការប៉ះទង្គិចគ្នានៅតាមព្រំដែនរវាងកម្ពុជា និងវៀតណាម
# ការប៉ះទង្គិចគ្នាពីបញ្ហានីតិវិធីរវាងព្រះរាជអាជ្ញា និងមេធាវីការពារក្តី

*ដោយឡូរ៉ា ម៉ាក់ដូណល់*

*ថ្ងៃទី២៥ ខែសភា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

## *វៀតណាមតទល់នឹងកម្ពុជា*

អន្តជំនុំជម្រះសាលាដំបូងបានផ្អាកការធ្វើកសិណសាក្សីជំនាញរបស់ ក្រេក អេតឆេសាន់ ស្តីពីរចនាសម្ព័ន្ធ និងគោលនយោបាយរបស់ខ្មែរក្រហមដើម្បីមកស្តាប់កសិណសាក្សីជំនាញរបស់ ណាយ៉ាន់ ចាន់ដា ស្តីពីជម្លោះប្រដាប់អាវុធដែលបានកើតឡើងរវាងកម្ពុជា និងវៀតណាមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ក្នុងចំណោមសមត្ថភាពអាជីពវិជ្ជាជីវៈជាច្រើនរបស់លោក, ណាយ៉ាន់ ចាន់ដា បានសិក្សាពីតំបន់ឥណ្ឌូចិនសម្រាប់ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា ក្នុងរយៈពេលយូរគួរសម ហើយបន្ទាប់មកទៀតលោក ក៏បានសរសេរសៀវភៅមួយក្បាលទាក់ទិននឹងការស្រាវជ្រាវរបស់លោកដែលមានចំណងជើងថា សត្រូវបងប្អូនឯង : សង្គ្រាមបន្ទាប់ពីសង្គ្រាម ។ បច្ចុប្បន្ន ណាយ៉ាន់ ចាន់ដា គឺជានាយកបោះពុម្ពផ្សាយ និងជាបណ្ណាធិការរបស់ទស្សនាវដ្តី YaleGlobal Online នៅឯមជ្ឈមណ្ឌលយ៉ែលសម្រាប់ការសិក្សាស្រាវជ្រាវពីសកលូបនីយកម្ម ។

ក្នុងអំឡុងពេលសួរសំណួរជាច្រើនម៉ោងពីចៅក្រម ស៊ីលវៀ ខាត់វ៉ាយថ៍, ណាយ៉ាន់ ចាន់ដា បានរៀបរាប់ពីជម្លោះប្រដាប់អាវុធនៅតាមព្រំដែនកម្ពុជា-វៀតណាម ដែលចាប់ផ្តើមក្នុងឆ្នាំ១៩៧៥ ហើយមានសភាពថយចុះក្នុងឆ្នាំ១៩៧៦ ក្រោយមកកាន់តែមានសភាពតានតឹងឡើងចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខណៈពេលដែលកងទ័ពវៀតណាមបានក្តោបក្តាប់ទីក្រុងភ្នំពេញ ។ ណាយ៉ាន់ ចាន់ដា បានរៀបរាប់ពីជម្លោះដែលកើតមាននៅតាមកោះមួយចំនួននៅតាមឈូងសមុទ្រថៃ ការទម្លាក់គ្រាប់បែកលើភូមិជាច្រើនលើព្រំដែនទាំងសងខាងរបស់ប្រទេសទាំងពីរ និងការបណ្តេញប្រជាជនវៀតណាម និងអ្នកគាំទ្រវៀតណាមចេញពីប្រទេសកម្ពុជា ។ ដោយសារតែរយៈពេលសាមសិបឆ្នាំបានកន្លងផុតទៅ ការចងចាំពីព័ត៌មានជាក់លាក់មួយចំនួននៅក្នុងសៀវភៅ សត្រូវបង

ប្អូន របស់ ណាយ៉ាន់ ចាន់ដា បានបាត់បង់ខ្លះ ប៉ុន្តែក្នុងពេលឥឡូវនេះ លោកអាចរៀបរាប់ពីព្រឹត្តិការណ៍ និងបទសម្ភាសន៍បានយ៉ាងក្បោះក្បាយ ។ លោកក៏បានលើកឡើងពីដំណើរទស្សនកិច្ចរបស់លោកទៅកាន់ភូមិមួយនៅតាមព្រំដែនវៀតណាមកាលពីខែមីនា ឆ្នាំ១៩៧៨ ដែលលោកនៅតែមានសុបិន្តអាក្រក់បន្ទាប់ពីដំណើរទស្សនកិច្ចនោះមក ។ លោកបាននិយាយថា ភូមិនោះមើលទៅគឺមានសភាព ដូចជាត្រូវបាន«វាយបក់បោកដោយព្យុះ» ហើយសាកសពប្រជាជនស៊ីវិលបុរស-ស្ត្រី និងកុមារតំរៀបជាជួរនៅតាមដងផ្លូវ ។ នៅក្នុងផ្ទះខ្ទមពោរពេញដោយភក់ លោកបានឃើញពាក្យមួយឃ្លាដែលសរសេរជាភាសាខ្មែរថា «នេះគឺជាទឹកដីរបស់យើង» ។

ណាយ៉ាន់ ចាន់ដា បានពន្យល់ថាសហគមន៍អន្តរជាតិមិនបានដឹងពីឆ្នាំដំបូងនៃជម្លោះនេះទេ ពីព្រោះថាទាំងមន្ត្រីវៀតណាមនិងកម្ពុជា ព្យាយាមរក្សាការសម្ងាត់ពីសង្គ្រាមនេះ ។ បើទោះបីជាការវាយប្រហារគ្នាចាប់ផ្តើមជាដំបូងនៅក្នុងទឹកដីវៀតណាមក៏ដោយ ក៏វៀតណាមមានការប្រុងប្រយ័ត្ន ធ្វើយ៉ាងណាមិនឲ្យខ្មែរក្រហមមានការខឹងសម្បាដែរ ពីព្រោះវៀតណាមិនចង់បង្កឲ្យមានសង្គ្រាមរាលដាលពេញប្រទេសឡើយ ។ យ៉ាងណាមិញ ក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ ខ្មែរក្រហមមានទំនាក់ទំនងការទូតកាន់តែតានតឹងជាមួយវៀតណាម ហើយបានប្រកាសកាន់កាប់ប្រទេសកម្ពុជាជាសាធារណៈ ។ មួយរយៈពេលខ្លីក្រោយមកវៀតណាមបានចាប់ផ្តើមការវាយប្រហារទ្រង់ទ្រាយធំមកលើទឹកដីកម្ពុជា ។

ចៅក្រម និងព្រះរាជអាជ្ញា បានចំណាយពេលយ៉ាងច្រើនដើម្បីចោទសួរ ណាយ៉ាន់ ចាន់ដា ពីមូលហេតុនិងប្រភពដើមនៃជម្លោះនេះ ។ ជាសរុបមក ណាយ៉ាន់ ចាន់ដា បានពន្យល់ថា ប្រទេសវៀតណាមបានព្យាយាមធ្វើឲ្យមាន«ចំណងមិត្តភាពពិសេស»ជាមួយប្រទេសឡាវនិងកម្ពុជា ដោយមានជំនឿថា ប្រទេសទាំងបីគួរតែសហការរួបរួមគ្នាដើម្បីការពារអធិបតេយ្យភាព និងប្រព័ន្ធពិសេសរបស់ខ្លួន ។ នៅពេលដែល ប៉ុល ពត ឡើងកាន់កាប់អំណាច ប៉ុល ពត បានសម្រេច និងប្រកាសឲ្យដឹងថា បក្សរបស់ខ្លួនមិនយកលំនាំគេ និងមិនមានជាប់ពាក់ព័ន្ធនឹងវៀតណាមឡើយ ។ ណាយ៉ាន់ ចាន់ដា បានធ្វើការពិភាក្សាវែកញែកពីការឃោសនារបស់ខ្មែរក្រហមពី«អ្នកប្រកាន់ពូជសាសន៍» ដោយចាត់ទុកជនជាតិវៀតណាមជាមនុស្សសាហាវព្រៃផ្សៃ និងជាជនវាតទី ។ មាគ៌ាបក្សមួយនេះបានធ្វើឲ្យអ្នកដែលមានសេចក្តីអាណិតអាសូរនិងទំនាក់ទំនងជាមួយវៀតណាម ក្លាយជាសត្រូវនឹងប្រទេសកម្ពុជា ។ បើទោះបីជាវិវាទទឹកដីគឺជាចំណុចឆ្លុះបញ្ចាំងពីជម្លោះរវាងកម្ពុជានិងវៀតណាមក៏ដោយ ក៏ ណាយ៉ាន់ ចាន់ដា បានព្យាយាមបង្ហាញពីប្រវត្តិដ៏ស្មុគស្មាញ និងយូរអង្វែងដែលនៅពីក្រោយវិវាទទាំងនេះ ។

ជនត្រូវចោទ កាំង ហ្កេចអ៊ាវ (ឌុច) មិនបានជំទាស់នឹងការកើតមានឡើងនូវជម្លោះប្រដាប់អាវុធនេះទេ។ ឌុច បានអះអាងថា ខ្លួនបានឮពីជម្លោះនេះ ប៉ុន្តែមិនបានដឹងជាព័ត៌មានលម្អិតនោះទេ។ ក្នុងថ្ងៃនេះ ឌុច បានកត់សម្គាល់ថា ខ្លួនមានជំនឿជឿជាក់ចំពោះ ប៉ុល ពត អាចរក្សាបាននូវអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ។

## ច្បាប់ស៊ីវិលឡូ (Civil Law) និងខមិនឡូ (Common Law)

បន្ទាប់ពីព្រះរាជអាជ្ញាបានសួរសំណួរទៅកាន់ ណាយ៉ាន់ ចាន់ដា អស់រយៈពេលមួយម៉ោងជាងក្រោយមក ហ្វ្រង់ស៊័រ រ៉ូ មេធាវីការពារក្តីអន្តរជាតិបានក្រោកឈរលើកឡើងពីសេចក្តីជំទាស់របស់លោក ។ រ៉ូ បានអះអាងថា ទម្រង់បែបបទនៃច្បាប់ខមិនឡូរបស់ព្រះរាជអាជ្ញាក្នុងការសួរបញ្ជាក់ពីភស្តុតាងដែលមានរួចជាស្រេចហើយនោះមិនមានសារសំខាន់ទេ ហើយវាគឺជា“ការចំណាយពេលឥតប្រយោជន៍”ក្នុងបរិបទច្បាប់ស៊ីវិលឡូ ដែលការស៊ើបអង្កេតត្រូវបានធ្វើឡើងអស់រយៈពេលជាងមួយឆ្នាំ ហើយដែលចៅក្រមបានចោទសួរសាក្សីយ៉ាងម៉ត់ចត់រួចទៅហើយនេះ ។ រ៉ូ បាននិយាយបន្ថែមទៀតថាព្រះរាជអាជ្ញាបានកំពុងតែប្រើប្រាស់សាក្សីរូបនេះដោយមិនស្មើភាពដើម្បីរៀបចំជាភស្តុតាងប្រឆាំងនឹង អៀង សារី និង ខៀវ សំផន ហើយរួមទាំងមន្ត្រីខ្មែរក្រហមផ្សេងទៀតដែលរងការចោទប្រកាន់ដែលឈ្មោះរបស់មន្ត្រីទាំងនេះ ត្រូវបានលើកឡើងក្នុងអំឡុងពេលធ្វើកសិណសាក្សីរបស់ ណាយ៉ាន់ ចាន់ដា ។

អាឡិចសាន់ឌឺ ប៊ិត សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថាការជំទាស់របស់ ហ្វ្រង់ស៊័រ រ៉ូ គឺជាការចំណាយពេលឥតប្រយោជន៍ ហេតុដូច្នេះលោកសុំមិនធ្វើការទទួលស្គាល់ចំពោះបទចោទប្រកាន់ផ្សេងទៀតជាមួយនឹងការឆ្លើយតបបែបនេះទេ។ អាឡិចសាន់ឌឺ ប៊ិត បានធ្វើការកត់សម្គាល់ថា ណាយ៉ាន់ ចាន់ដា មិនបានកោះហៅឲ្យមកធ្វើកសិណសាក្សីក្នុងអំឡុងពេលដំណើរការស៊ើបអង្កេតនៃសំណុំរឿងនេះទេ ហើយដូច្នេះព្រះរាជអាជ្ញាបានកំពុងព្យាយាមទាញយកសមត្ថភាពដ៏ជំនាញនេះ និងធ្វើឲ្យ ណាយ៉ាន់ ចាន់ដា អាចបង្ហាញប្រាប់ពីការយល់ដឹងទាំងប៉ុន្មានរបស់លោក ទាក់ទិននឹងគោលនយោបាយរបស់ប្រទេសកម្ពុជានិងវៀតណាម ។

ក្រុមមេធាវីដើមបណ្តឹងទាំងបួនបាននិយាយគាំទ្រព្រះរាជអាជ្ញា រួមទាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ីលឃី ស្តូតហ្វ៊ីនស្តី ដែលបានរំលឹកថាអ្នករាល់គ្នាបានស្តាប់ពីចំណាប់អារម្មណ៍របស់ ហ្វ្រង់ស៊័រ រ៉ូ

ស្តីពីប្រព័ន្ធច្បាប់ស៊ីវិលឡូ និងច្បាប់ខមិនឡូ រួចម្តងហើយ ហើយច្បាប់ទាំងពីរនេះមិនចាំបាច់លើកឡើងម្តងហើយម្តងទៀតនោះទេ។ ចៅក្រមបានសម្រេចថា ការជំទាស់របស់ ហ្វ្រង់ស៊័រ រូ «មិនសមហេតុផល» ហើយបានអនុញ្ញាតឲ្យព្រះរាជអាជ្ញាបន្តចោទសួរ ណាយ៉ាន់ ចាន់ដា ។

ណាយ៉ាន់ ចាន់ដា នឹងវិលត្រឡប់មកបញ្ចប់កសិណសាក្សីរបស់លោកស្តីជម្លោះប្រដាប់អាវុធនៅថ្ងៃស្អែក ។